**សំណួរ**

**អ្វីទៅជាវិធានទំនៀមទម្លាប់អន្តរជាតិ?**

**ចម្លើយ**

មាត្រា ៣៨ នៃ លក្ខន្តិកៈរបស់ តុលាការយុត្តិធម៌អន្តរជាតិ បានចែងអំពី ច្បាប់អនុវត្ត នៅមុខតុលាការនេះ ។ ក្នុងនោះ មាត្រា ៣៨ បានចែងយោងដល់ កតិកាសញ្ញា ដែលរដ្ឋជម្លោះជាភាគី និងវិធានដទៃទៀត ដូចជា វិធានទំនៀមទម្លាប់អន្តរជាតិ។[1] តើអ្វីទៅ ជាវិធានទំនៀមទម្លាប់អន្តរជាតិ?

វិធាននេះ ជាការអនុវត្តជាទូទៅដោយរដ្ឋ (ធាតុផ្សំទី១) និងការយល់ថា ការអនុវត្តនេះ ដោយសារកត្តាចាប់បង្ខំ(ធាតុផ្សំទី២)។ ការអនុវត្តទូទៅ សំដៅដល់ការអនុវត្តដោយរដ្ឋភាគច្រើន តែមិនតម្រូវដោយគ្រប់រដ្ឋទាំងអស់នោះទេ (ការអនុវត្តជាសកល)។ ឧទាហរណ៍ បើរដ្ឋក្នុងពិភពលោកភាគច្រើន មិនប្រព្រឹត្តិអំពើទារុណកម្ម លើមនុស្ស (ការអនុវត្ត) នេះវាគ្រប់គ្រាន់សម្រាប់ធាតុផ្សំទីមួយហើយ។ ការមិនធ្វើទារុណកម្ម ដោយសាររដ្ឋ ជឿថាមានច្បាប់សីលធម៌ មនុស្សធម៌ ច្បាប់សាសនា វិធានច្បាប់ជាតិ ឬអន្តរជាតិដទៃទៀត (ដែលរដ្ឋមិនទាន់ទទួលស្គាល់) បានហាមឃាត់។

ក្នុងន័យនេះ ការបង្ហូតទម្លាក់ទង់ជាតិ ដោតលើកប៉ាល់របស់ខ្លួន នាពេលកប៉ាល់នោះ ចូលដល់សមុទ្រអន្តរជាតិ ជាការអនុវត្ត ក៏ប៉ុន្តែ ជាការសម្តែងគួរសម ចំពោះដែនសមុទ្រអន្តរជាតិ ដែលប្រទេសណា ក៏អាចធ្វើនាវាចរណ៍បានដែរ។ ការអនុវត្តនេះ គ្មានការបង្ខំទេ ហើយប្រសិនបើមិនធ្វើតាម ក៏មិនខុសនឹងវិធានអ្វីទេ។ វាជាការអនុវត្ត តែមិនតម្រូវ ឬ ទាមទារដោយច្បាប់ (no legal implication)។ វាជាការអនុវត្តបំពេញនូវធាតុផ្សំទី១ តែខ្វះធាតុផ្សំទី២។ ដូចនេះ យើងមិនអាចចាត់ថា ជាវិធានទំនៀមទម្លាប់អន្តរជាតិទេ។

<u>**Further Readings**</u>: Jean-Maries Henckaerts, Customary International Humanitarian Law, Volume I: Rules, 2009; Customary International Law, Selective Bibliography for the 70th session of the International Law Commission; Laurence R. Helfer & Ingrid B. Wuerth, Customary International Law: An Instrument Choice Perspective, 37 Mich. J. Int'l L. 563 (2016). Available at: http://repository.law.umich.edu/mjil/vol37/iss4/1.

---

[1] United Nations, *Statute of the International Court of Justice*, 18 April 1946, available at: https://www.refworld.org/docid/3deb4b9c0.html [accessed 28 August 2019]